ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**

លេខ:..................................គ.ម.ក

# លទ្ធផលកិច្ចប្រជុំ
# គណៈកម្មការមូលបត្រកម្ពុជាលើកទី ៤២

នៅរសៀលថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ **ឯកឧត្តមបណ្ឌិត អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក**) បានអញ្ជើញដឹកនាំកិច្ចប្រជុំ **គ.ម.ក** លើកទី ៤២ ដើម្បីពិនិត្យ និងអនុម័តលើរបៀបវារៈសំខាន់ៗចំនួន ៣ គឺ÷

១. ពិនិត្យ និងអនុម័តលើគម្រោងថវិកា និងផែនការលទ្ធកម្មរបស់ **គ.ម.ក.** សម្រាប់ឆ្នាំ២០១៦។

២. ពិនិត្យ និងអនុម័តជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ របស់ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី។

៣. ផ្សេងៗ។

បន្ទាប់ពីមន្ត្រីជំនាញធ្វើបទបង្ហាញជូនអង្គប្រជុំរួចមក អង្គប្រជុំបានពិភាក្សាផ្លាស់ប្តូរយោបល់យ៉ាងផុសផុល ទាំងកម្រិតបច្ចេកទេស និងគោលនយោបាយទៅលើឯកសារដែលរៀបចំដោយនាយកដ្ឋានជំនាញនៃ **គ.ម.ក.** ហើយអង្គប្រជុំបានសម្រេចដូចខាងក្រោម÷

១. អនុម័តលើគម្រោងថវិកា និងផែនការលទ្ធកម្មរបស់ **គ.ម.ក.** សម្រាប់ឆ្នាំ២០១៦ ដើម្បីធានានិរន្តរភាពនៃកិច្ចដំណើរការរបស់ **គ.ម.ក.**។

២. អនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈរបស់ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី ដែលជាក្រុមហ៊ុនអភិវឌ្ឍ និងជាប្រតិបត្តិករនៃតំបន់សេដ្ឋកិច្ចពិសេស ទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលកាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៦ ធ្វើប្រតិបត្តិការលើផ្ទៃដីសរុបចំនួន ៣៥៧,៣២ ហិកតា។ ក្រុមហ៊ុនត្រូវបន្តនីតិវិធីនៃការធ្វើប៊ុកបៀលឌីង (Book-building) និងរៀបចំសំណើលក់ដើម្បីស្នើសុំការអនុញ្ញាតចុះបញ្ជីឯកសារផ្តល់ព័ត៌មានជាស្ថាពរពី **គ.ម.ក** អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ដោយឡែកក្នុងរបៀបវារៈផ្សេងៗ អង្គប្រជុំបានស្តាប់ការរាយការណ៍អំពីវឌ្ឍនភាពរបស់ក្រុមហ៊ុនដែលបានដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ និងណែនាំដល់មន្ត្រីជំនាញឱ្យបន្តការងារដោយយកចិត្តទុកដាក់ខ្ពស់ ព្រមទាំងវាយតម្លៃខ្ពស់លើសមិទ្ធផលដែលសម្រេចបានកន្លងមក។

អង្គប្រជុំបានបញ្ចប់នៅម៉ោង ៥ និង ១៥ នាទីល្ងាចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦

**គណៈកម្មការមូលបត្រកម្ពុជា**

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Temporary Address: #99 Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia www.secc.gov.kh
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh